FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ

បោះពុម្ពលើកទី១ ឆ្នាំទី១៣ លេខ១ ខែមីនា ឆ្នាំ២០១៤

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute



# ពូជស្រូវធ្ងន់ "ដំណើបស្បៃមង្គល"

ពូជស្រូវ "**ដំណើបស្បៃមង្គល**" ជាពូជស្រូវដំណើបទី១ ដែលបានធ្វើការបញ្ចេញ និងផ្សព្វផ្សាយជូនកសិករប្រើប្រាស់ដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាចុងឆ្នាំ២០១៣។ **ពូជស្រូវ "ដំណើបស្បៃមង្គល"** ជាពូជស្រូវដែលបានសម្រិតសម្រាំងតាមបច្ចេកទេសរុក្ខជម្រើសវិទ្យា ពីពូជស្រូវប្រពៃណីដែលបានប្រមូលយកមករក្សាទុកនៅក្នុងធនាគារពន្ធុក្នុងវិទ្យាស្ថាន។

## លក្ខណៈពិសេសៗរបស់ពូជស្រូវដំណើបស្បៃមង្គល

**ពូជស្រូវ "ដំណើបស្បៃមង្គល"** ជាពូជស្រូវធ្ងន់ប្រកាន់រដូវ ចាប់ចេញផ្កាក្នុងអាទិត្យទី២ ខែវិច្ឆិកា អាស្រ័យទៅលើអាកាសធាតុ និងពេលវេលាដាំដុះ។ កម្ពស់ដើមរបស់ពូជស្រូវ**ដំណើបស្បៃមង្គល** ប្រែប្រួលពី១៤០-១៦០ ស.ម និងចំនួនដើមបែកផ្តល់ផលគឺចាប់ពី៨-១០ ដើមក្នុងមួយគុម្ព អាស្រ័យទៅតាមប្រភេទដី។ ចំនួនគ្រាប់ក្នុងមួយកួរមានចាប់ពី១០០-១២០គ្រាប់ និងមានប្រវែងកួរ២៦-៣០ ស.ម។ គ្រាប់ស្រូវ១០០ គ្រាប់មានទម្ងន់៣,៤ ក្រាម និងមានទិន្នផលជាមធ្យម៣,២ តោនក្នុង១ហិកតា។ អង្ករលេខ្លួនវែង មានប្រវែងគ្រាប់ជាមធ្យម៧,២ មីលីម៉ែត្រ បន្ទារកម្រាស់ជាមធ្យម២,១ មីលីម៉ែត្រ និងមានអាមីឡូស ១,៦ ភាគរយ។ ពូជស្រូវ**ដំណើបស្បៃមង្គល** ធន់មធ្យមទៅនឹងរាំងស្ងួត និងធន់បានល្អនឹងទឹកជំនន់។

## វិធីសាស្ត្រដាំដុះ

**សម្រាប់ស្រូវសន្ទូង** បរិមាណគ្រាប់ពូជដែលចាំបាច់គឺពី៣០-៤០ គីឡូក្រាម ក្នុងមួយហិកតា ប៉ុន្តែក្នុងករណីដែលគ្រាប់ពូជសុទ្ធ និងមានសុខភាពល្អ ព្រមទាំងគ្រប់គ្រងទឹកបាន និងថែទាំបានល្អ បរិមាណគ្រាប់ពូជដែលត្រូវការក្នុងមួយហិកតា គឺពី១៥-២០ គីឡូក្រាមប៉ុណ្ណោះ។ ដើម្បីឲ្យសំណាបដុះលូតលាស់ធំធាត់ល្អ គេត្រូវសាបគ្រាប់ពូជ មួយគីឡូក្រាមលើផ្ទៃដីថ្នាល ១០ ម៉ែត្រការ៉េ។ ទីសំណាបត្រូវធ្វើនៅជិតប្រភពទឹក តែត្រូវឆ្ងាយពីម្លប់ព្រៃ ឬកន្លែងមានភ្លើងអគ្គីសនី ដើម្បីចៀសវាងការបំផ្លាញពីសត្វល្អិតចង្រៃ។ ជាការល្អ គួរស្ទូងសំណាបដែលមានអាយុ២៥-៣០ ថ្ងៃ ហើយក្នុងមួយគុម្ពចំនួន២-៣ ដើម។ សម្រាប់ស្រូវពង្រោះ បរិមាណគ្រាប់ពូជដែលចាំបាច់គឺពី៦០-៨០ គីឡូក្រាមក្នុងមួយហិកតា។ គួររៀបចំដីឲ្យបានល្អ និងរាបស្មើមុនស្ទូង ឬព្រោះ។ ការភ្ជួររាស់ គួរតែធ្វើឲ្យបាន២-៣ សារជាការល្អប្រសើរ។ ប្រសិនបើស្រែអាចបញ្ចេញបញ្ចូលទឹកបានបន្ទាប់ពីស្ទូង ឬព្រោះបាន២០ ថ្ងៃអាចបញ្ចេញទឹកឲ្យអស់ពីក្នុងស្រែ២-៤ ថ្ងៃរួចបញ្ចូលទឹកថ្មីវិញ។ ធ្វើរបៀបនេះ គឺដើម្បីធ្វើឲ្យស្រូវកាន់តែបែកគុម្ពល្អ។







## ការប្រើប្រាស់ជី

ការប្រើប្រាស់ជីសមស្របតាមកម្រិតណែនាំ នឹងមិនបណ្តាលឲ្យមានការថយចុះគុណភាពឡើយ។ គួរដាក់ជី២-៣ ដងក្នុងមួយវដ្តជីវិតរបស់ស្រូវ។ បាចទ្រាប់បាតមុនពេលស្ទូងដោយប្រើជីធម្មជាតិពី៥ តោន (២០ រទេះ) ក្នុង១ ហិកតា និងរួមផ្សំជាមួយជីគីមីដូចមានក្នុងតារាង១។ បរិមាណជីបាចបំប៉នលើកទីមួយ និងលើកទីពីរ ត្រូវអនុលោមតាមតារាង១ ហើយពេលវេលានៃការបាច ត្រូវអនុលោមតាមតារាង២។



តារាង១

| ក្រុមដី | ស្រូវធ្ងន់ (ស្រូវវស្សា) | | | | |
|---|---|---|---|---|---|
| | បាចទ្រាប់បាតមុនស្ទូង ឬព្រោះ (គ.ក្រ/ហាត) | | | បំប៉នអ៊ុយរ៉េ (គ.ក្រ/ហាត) | |
| | អ៊ុយរ៉េ ៤៦-០-០ | ដេ អា ប៉េ ១៨-៤៦-០ | ប៉ូតាស្យូ ០-០-៦០ | លើកទី ១ | លើកទី ២ |
| ដីព្រៃខ្មែរ | ១០ | ២០ | ៤០ | ២០ | ១០ |
| ដីប្រទះឡាង | ១០ | ៥០ | ២៥ | ២៥ | ២៥ |
| ដីបាកាន ឬអូររាំង | ២៥ | ២៥ | ២៥ | ៥០ | ២៥ |
| ដីទួលសំរោង | ២៥ | ៥០ | ០ | ២៥ | ២៥ |
| ដីគោកត្រប់ | ១០ | ៥០ | ៥០ | ៤០ | ៣៥ |
| ដីកំពង់សៀម | ៣០ | ០ | ០ | ៤០ | ៣០ |
| ដីក្បៀនស្វាយ | ជាដីតាមមាត់ច្រាំងទន្លេ និងជម្រាលពីច្រាំងទន្លេសមស្របសម្រាប់ស្រូវស្រាល | | | | |
| ដីក្រគរ | ជាដីលិចទឹករយៈពេលយូរ ដែលកសិករធ្វើស្រូវឡើងទឹក ឬប្រដេញទឹក | | | | |
| ដីក្បាលពោធិ | | | | | |

តារាង២

| ពេលវេលាសាប | បំប៉នលើកទី ១ | បំប៉នលើកទី ២ |
|---|---|---|
| ១-៣១ មិថុនា | ៣០ ថ្ងៃក្រោយស្ទូង | ៥-៩ កញ្ញា |
| ១-១៥ កក្កដា | ៣០ ថ្ងៃក្រោយស្ទូង | ១០-១៤ កញ្ញា |
| ១៦-៣០ កក្កដា | ៣០ ថ្ងៃក្រោយស្ទូង | ១៥-១៩ កញ្ញា |

## ការប្រមូលផល

- ត្រូវប្រមូលផលស្រូវនៅពេលគ្រាប់ទុំល្អ គឺនៅពេលដែលកួរស្រូវមានគ្រាប់ចាប់ពីពាក់កណ្តាលកួរឡើងទៅមានពណ៌លឿងទុំចាស់ និងគ្រាប់ពេញពាក់កណ្តាលកួរចុះក្រោមមានពណ៌លឿងទុំស្រាល ហើយគ្រាប់ស្កកវិញមានពណ៌ស្លាបសេកចាស់។
- គេអាចហាលសម្ងួតស្រូវនៅលើកន្ទេល សំណាញ់មុង តង់កៅស៊ូ និងលានស៊ីម៉ង់ត៍ គឺមិនបណ្តាលឲ្យគុណភាពគ្រាប់ស្រូវ ឬគ្រាប់ស្រូវពូជខុសគ្នាឡើយ។ កម្រាស់គ្រាប់ស្រូវដែលសមស្របសម្រាប់ការហាលសម្ងួតគឺ២-៣ ស.ម ដែលកម្រាស់គ្រាប់ និងសភាពពន្លឺថ្ងៃគឺជា កត្តាចម្បងក្នុងការកំណត់រយៈពេលហាលនិងគុណភាពគ្រាប់ស្រូវ៖
  - ថ្ងៃស្រឡះល្អ ហាលតែ១ ថ្ងៃ ប៉ុណ្ណោះ ដោយកន្លះម៉ោងរឹម្តង។
  - ថ្ងៃស្រឡះបង្គួរ ហាលសម្ងួតរយៈពេល២ ថ្ងៃដោយ១ ម៉ោងរឹម្តង។
  - ថ្ងៃមិនស្រឡះ គេត្រូវហាលរហូតដល់៣ ថ្ងៃដោយ២ ម៉ោងរឹម្តង។
- គ្រាប់ពូជត្រូវច្រកទុកនៅក្នុងថង់ប្លាស្ទិកចងឲ្យជិត រួចដាក់ក្នុងបាវមួយជាន់ទៀត ហើយទុកដាច់ដោយឡែកពីគ្រាប់ស្រូវចំណីនៅកន្លែងដែលស្ងួតល្អ និងគ្មានការបំផ្លាញពីសត្វកណ្តុរ មាន់ ទាជាដើម។ ត្រូវសរសេរឈ្មោះពូជ និងថ្ងៃខែច្រូតកាត់ដាក់នៅលើបាវឲ្យបានត្រឹមត្រូវល្អ។
- ផលស្រូវដែលប្រមូលបាន ត្រូវទុកដាក់ក្នុងជង្រុកឲ្យបានល្អ ដោយការពារកុំឲ្យសត្វកណ្តុរ មាន់ ទាស៊ី និងមិនឲ្យទទឹក។



សម្រាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យរុក្ខជម្រើសវិទ្យា មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ ភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ គេហទំព័រ: www.cardi.org.kh
ទូរអក្សរ: ssophany@cardi.org.kh trin@cardi.org.kh hunyadana@cardi.org.kh